# សុន្ទរកថា
# របស់ ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ
# និងជារដ្ឋមន្ត្រីស្តីទី ទីស្តីការគណៈរដ្ឋមន្ត្រី
# ថ្លែងក្នុងពិធីសម្ពោធពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ
# ក្នុងឱកាសយុទ្ធនាការទិញផលិតផលខ្មែរ

ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ១៥:៣០នាទី
ទីតាំង៖ បរិវេណមជ្ឈមណ្ឌលវិមានសុភមង្គល
សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

- ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម!
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយស ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានកិត្តិយសណាស់ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចាត់ឱ្យខ្ញុំជា តំណាង **សម្តេច** ចូលរួមជាអធិបតីក្នុងពិធីសម្ពោធ "**ពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ ក្នុងឱកាសយុទ្ធនាការទិញផលិតផលខ្មែរ** " ដែលចាប់ដំណើរការ ពីថ្ងៃនេះ រហូតដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៧។

ពិព័រណ៍ដ៏មានសារៈសំខាន់នេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងជំរុញសកម្មភាពពាណិជ្ជកម្ម ពង្រីកទីផ្សារ ទាំងក្នុង និងក្រៅប្រទេស បង្ហាញពីបរិយាកាសធុរកិច្ច និងសក្តានុពលវិនិយោគ ព្រមទាំងបង្ហាញអំពីគោលនយោបាយគាំពារវិនិយោគ និងធុរកិច្ច នៅកម្ពុជា។ តាមរយៈពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរថ្ងៃនេះ ខ្ញុំសង្ឃឹមថាអ្នកប្រើប្រាស់នឹងបានស្គាល់កាន់តែច្បាស់ ព្រមទាំងជួយគាំទ្រផលិតផលទំនិញក្នុងស្រុករបស់យើង។ ជាមួយនឹងការដាក់តាំងបង្ហាញផលិតផលទំនិញដែលនាំមកពីបណ្តាខេត្តនានានៅទូទាំងប្រទេស ក៏មានរៀបចំនូវការសម្តែងសិល្បៈ សម្រាប់ជូនបងប្អូនប្រជាពលរដ្ឋយើងកំសាន្តផងដែរ។

ក្នុងនាម **សម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការកោតសរសើរដ៏ស្មោះ និងវាយតម្លៃខ្ពស់ចំពោះស្នាដៃ និងកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងពាណិជ្ជកម្ម ដែលបានរៀបចំ "**ពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ ក្នុងឱកាស**

**យុទ្ធនាការទិញផលិតផលខ្មែរ**" នេះបានល្អប្រសើរ ដែលជាឱកាសដ៏ល្អ និងសមស្របមួយសម្រាប់ជំរុញពលរដ្ឋយើងឱ្យនិយមប្រើផលិតផលខ្មែរ។

ការចូលជាធរមាន នៃសហគមន៍សេដ្ឋកិច្ចអាស៊ានតាំងពីខែមករា ឆ្នាំ២០១៥ ជាឱកាសដែលមានវិសាលភាពពង្រីកទីផ្សារនាំចេញសម្រាប់ផលិតផលយើងផង តាមរយៈការតភ្ជាប់ពាណិជ្ជកម្មរវាងកម្ពុជា និងអាស៊ាន។ ក៏ប៉ុន្តែជាមួយគ្នានេះ រោងចក្រ សហគ្រាស សិប្បកម្ម និងផលិតកម្មទាំងឡាយនៅកម្ពុជា នឹងជួបប្រទះនូវការប្រកួតប្រជែងថ្មីមួយ ដែលមានលក្ខណៈកាន់តែខ្លាំង និងកាន់តែលំបាកជាងមុនពីសំណាក់ប្រទេសនានាក្នុងអាស៊ាន។

ចំពោះមុខសភាពការណ៍នេះ និងក្នុងគោលបំណងជួយរោងចក្រ សហគ្រាស សិប្បកម្ម និងផលិតកម្មទាំងឡាយនៅក្នុងប្រទេស រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងពាណិជ្ជកម្មជាសេនាធិការលើការអភិវឌ្ឍវិស័យពាណិជ្ជកម្ម បានផ្តួចផ្តើមគំនិតរៀបចំ **"យុទ្ធនាការទិញផលិតផលខ្មែរ"** ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដើម្បីបំផុសឱ្យពលរដ្ឋកម្ពុជា ងាកមកប្រើប្រាស់ផលិតផលខ្មែរ ជំនួសឱ្យការប្រើប្រាស់ផលិតផលនាំចូលពីបរទេស ជាពិសេសពីបណ្តាប្រទេសជាសមាជិកអាស៊ាន ដែលបានផលិត ផលិតផលទំនិញ ប្រហាក់ប្រហែលនឹងផលិតផលទំនិញដែលយើងផលិត និងនិយមប្រើ។

តាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្ម **យុទ្ធនាការទិញផលិតផលខ្មែរ** ត្រូវបានរៀបចំមួយរជូវកាលមកហើយ នៅឆ្នាំ២០១៦។ ដោយទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់មហាជនទូទៅ នៅឆ្នាំ២០១៧ ក្រសួងពាណិជ្ជកម្ម បាន និងកំពុងរៀបចំយុទ្ធនាការទិញផលិតផលខ្មែរ រដូវកាលទី២ ចំនួន៤ខេត្ត-រាជធានីទៀត។ ខ្ញុំជឿជាក់ថា ក្រសួងពាណិជ្ជកម្ម នឹងបន្តរៀបចំ **"ពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ ក្នុងឱកាសយុទ្ធនាការទិញផលិតផលខ្មែរ"** នៅខេត្តផ្សេងទៀត នៅឆ្នាំខាងមុខ ដើម្បីជំរុញប្រជាពលរដ្ឋខ្មែរឱ្យនិយមប្រើទំនិញរបស់ជាតិយើង មុននឹងប្រើទំនិញបរទេស។ ការរៀបចំ និងចូលរួមតាំងពិព័រណ៍ពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេស បានរួមចំណែកធ្វើឱ្យពាណិជ្ជកម្ម កម្ពុជាសម្រេចបាននូវកំណើនល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ។ ការកើនឡើងនូវទំហំពាណិជ្ជកម្ម ប្រកបដោយចីរភាពនេះ គឺដោយសារតែរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយ **គតិបណ្ឌិត** និង **ចក្ខុវិស័យនយោបាយខ្ពស់** របស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** មានគោលនយោបាយច្បាស់លាស់ យកចិត្តទុកដាក់ ជំរុញគាំពារវិនិយោគ និងធុរកិច្ចក្នុងប្រទេស ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារ ព្រមទាំងចាត់ទុកវិស័យឯកជនជាដៃគូយ៉ាងសំខាន់របស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដែលបាននាំមកនូវការអភិវឌ្ឍលើគ្រប់វិស័យ ដែលទាំងអស់គ្នាមើលឃើញសព្វថ្ងៃនេះ។

**"យុទ្ធនាការទិញផលិតផលខ្មែរ"** គឺជាឱកាសរំលឹកខ្មែរយើង ឱ្យងាកមកប្រើប្រាស់ទំនិញដែលផលិតក្នុងស្រុក ដើម្បីកាត់បន្ថយការហូរចូលទំនិញពីបរទេស ព្រមទាំងជំរុញការនាំចេញផលិតផលខ្មែរ

ទៅក្រៅប្រទេស ដើម្បីរួមចំណែកជួយពង្រឹងសមត្ថភាពផលិតផលក្នុងស្រុក និងបង្កើនការងារធ្វើជូនប្រជាជនយើង។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ឆ្លៀតឱកាសនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះក្រសួងពាណិជ្ជកម្ម ជាពិសេស **ឯកឧត្តមរដ្ឋមន្ត្រី** ដែលបានអនុវត្តន៍កម្មវិធីកែទម្រង់ស៊ីជម្រៅ ប្រកបដោយជោគជ័យ ក្នុងគោលបំណងជួយសម្រួលដល់ការធ្វើធុរកិច្ចនៅកម្ពុជា។ លទ្ធផលនៃកំណែទម្រង់ទាំងនោះ រួមមាន ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម ការចុះបញ្ជីម៉ាក និងការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ។ល។

ការកែទម្រង់ទាំងនេះ បាន និងកំពុងសម្រួលដល់ប្រតិបត្តិការពាណិជ្ជកម្មនៅកម្ពុជា។ សមិទ្ធផលនៃការកែទម្រង់ទាំងនេះ បានផ្តល់នូវទំនុកចិត្តកាន់តែខ្លាំងថែមទៀតដល់វិស័យឯកជន ដែលកំពុងមានវត្តមានធ្វើធុរកិច្ចនៅកម្ពុជា និងរួមចំណែកកៀរគរវិនិយោគបរទេសឱ្យចូលមកបណ្តាក់ទុនថែមទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ដែលនឹងនាំឱ្យទំនិញយើងអាចប្រកួតប្រជែងជាមួយទំនិញនាំចូលពីបរទេស។

**"ពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ ក្នុងឱកាសយុទ្ធនាការទិញផលិតផលខ្មែរ"** ដែលកំពុងត្រូវបានរៀបចំនៅថ្ងៃនេះ គឺជាគំនិតផ្តួចផ្តើមដ៏ត្រឹមត្រូវ និងជាស្នាដៃថ្មីមួយទៀតរបស់ក្រសួងពាណិជ្ជកម្មក្នុងបេសកកម្មការងាររបស់ខ្លួន។ ខ្ញុំសង្ឃឹមយ៉ាងខ្លាំងថា **"យុទ្ធនាការទិញផលិតផលខ្មែរ"** នឹងក្លាយជាមធ្យោបាយថ្មីមួយ ជួយដាស់តឿនស្មារតីខ្មែរយើងឱ្យនិយមប្រើផលិតផលខ្មែរជាអតិបរមា។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសទាំងអស់** ដែលបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធពិព័រណ៍នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណ និងកោតសរសើរដល់ផលិតករទាំងអស់ ដែលអញ្ជើញមកពីគ្រប់ខេត្ត-ក្រុង ព្រមទាំងរាជធានីភ្នំពេញ ចូលរួមការតាំងពិព័រណ៍ដ៏ល្អ និងរស់រវើកនេះ។

ខ្ញុំសូមជូនពរឱ្យ **"ពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ ក្នុងឱកាសយុទ្ធនាការទិញផលិតផលខ្មែរ"** ប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងលទ្ធផលជាផ្លែផ្កា និងសូមជូនពរចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា សូមប្រកបដោយសុខភាពល្អបរិបូរណ៍ សុភមង្គល និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

ជាទីបញ្ចប់ក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំសូមប្រកាសបើក **"ពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ ក្នុងឱកាសយុទ្ធនាការទិញផលិតផលខ្មែរ"** ចាប់ពីពេលនេះតទៅ។

**សូមអរគុណ។**